អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញ

## ស្តីពី

# ផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សម្រាប់រយៈពេល ១០ឆ្នាំ (២០២១-២០៣០)

ដោយលោក **អ៊ឹម សុផល** ប្រធាននាយកដ្ឋានសវនកម្មទី២

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

# មាតិកា

១ គុណតម្លៃស្ថាប័ន

២ យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ

៣ សេចក្តីសន្និដ្ឋាន

# ១ គុណតម្លៃស្ថាប័ន

អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានប្រកាន់យកនូវគុណតម្លៃស្ថាប័នរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជំរុញការបំពេញការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទឱ្យមានភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំងទទួលខុសត្រូវខ្ពស់ក្នុងការបំពេញបេសកកម្មរួម។

គុណតម្លៃរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** រួមមាន÷

១. ក្រមសីលធម៌វិជ្ជាជីវៈ

២. ស្មារតីបុរេសកម្ម

៣. ប្រតិគុណ្យការ

៤. ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

៥. នវានុវត្តន៍

៦. គុណាធិបតេយ្យ

# ១ គុណតម្លៃស្ថាប័ន (ត)

**១.ក្រមសីលធម៌វិជ្ជាជីវ:**

សំដៅដល់ការអនុវត្តការងារ ដោយប្រតិបត្តិតាមគោលការណ៍សីលធម៌ ដែលកំណត់នូវសកម្មភាព និងអាកប្បកិរិយាក្នុងពេលបំពេញការងារ ដើម្បីរក្សាគុណតម្លៃ កិត្តិយស និងសេចក្ដីថ្លៃថ្នូរ នៃមន្ត្រីតាមរយៈការប្រកាន់ខ្ជាប់នូវ ឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការ វិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ព្រមទាំងគោរពយ៉ាងខ្ជាប់ខ្ជួននូវអភិក្រមទាំង ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.ស្មារតីបុរេសកម្ម**

សំដៅដល់ការអនុវត្តការងារ ដោយធ្វើការគិតយល់មុននូវលទ្ធភាពកើតមានបញ្ហា, ការប្រកាន់យកនូវគោលការណ៍មិនបង្កើតបញ្ហា, ការរៀបចំប្រព័ន្ធការងារដែលកាត់បន្ថយលទ្ធភាពដែលកើតមានបញ្ហា, ការត្រៀមលក្ខណៈសកម្មជានិច្ច ត្រៀមដោះស្រាយជាយថាហេតុ, ការមិនមើលបំណាំ មិនចោទប្រកាន់គ្នា, និងការគិតគូរដោះស្រាយបញ្ហាទាន់នៅទំហំតូច ចាត់វិធានការជាមុនដោយមិនរងចាំការណែនាំ។

## ១ គុណតម្លៃស្ថាប័ន (ត)

### ៣. ប្រតិគុណស្រ្តនារ

សំដៅដល់ការអនុវត្តការងារ ដោយធ្វើការពិចារណា ថ្លឹងថ្លែង បែងចែកតួនាទី ភារកិច្ច និងសិទ្ធិសម្រេច ប្រកបដោយយុត្តិធម៌ ដើម្បីធ្វើឱ្យថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីគ្រប់លំដាប់ថ្នាក់មានលំនឹងចិត្ត ការជឿជាក់ និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការអនុវត្តតួនាទី ភារកិច្ច ដោយឈរលើមាគ៌ាសុចរិត យុត្តិធម៌ បម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន។

### ៤. ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

សំដៅដល់ការអនុវត្តការងារ ដោយធ្វើការផ្តោតការយកចិត្តដាក់លើគុណភាពនៃលទ្ធផល ភាពសមស្របនៃចំណាយ និងវិធីសាស្រ្តក្នុងការអនុវត្តតួនាទី ភារកិច្ច ដោយឈរលើមាគ៌ាសុចរិត យុតិធម៌ បម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន។

## ១ គុណតម្លៃស្ថាប័ន (ត)

**៥.នវានុវត្តន៍**

សំដៅដល់ការអនុវត្តការងារ ដោយធ្វើការប្រើគំនិតកែច្នៃ និងការចូលរួមដោះស្រាយបញ្ហាប្រឈមជាក់ស្តែង តាមរយៈការបង្កើន ដំណោះស្រាយថ្មី ឬការច្នៃប្រឌិតលើស្នាដៃដែលមានស្រាប់ ដែលបង្កើតជាតម្លៃបន្ថែម។

**៦.គុណាធិបតេយ្យ**

សំដៅដល់ប្រព័ន្ធលើកទឹកចិត្តសមស្រប ផ្អែកលើសមត្ថភាព សមិទ្ធកម្ម ប្រសិទ្ធភាព វិន័យ នវានុវត្តន៍ និងសមធម៌ ដែលធានាសុចរិត ភាព និរន្តភាព និងកិត្យានុភាពស្ថាប័ន តាមគោលការណ៍ "លើកទឹកចិត្តផ្អែកលើគុណសម្បត្តិ និងបង្កើតគុណសម្បត្តិដើម្បីបានការលើកទឹកចិត្ត"។

# ② យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ

**១. យន្តការអនុវត្ត**

ដើម្បីសម្រេចបាននូវផែនការសកម្មភាពដែលបានដាក់ចេញ ទាមទារឱ្យមានយន្តការការងារច្បាស់លាស់។

ប្រធានអង្គភាព ជាអ្នកដឹកនាំអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន តាមការណែនាំ និងចង្អុលទិសពីក្រុមប្រឹក្សា អ.ស.ហ. និងពីសំណាក់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ. ដោយមានការសហការជាមួយអង្គភាពក្រោមឱវាទ **អ.ស.ហ.** ជាលក្ខខណ្ឌចាំបាច់បំផុតក្នុងក្របខ័ណ្ឌតួនាទី និងភារកិច្ចដែលមានអន្តរនិស្សរភាព (Interdependent) ។ ។

## ២ យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ (ត)

### ១. យន្តការអនុវត្ត (ត)

គ្រប់នាយកដ្ឋាន និងការិយាល័យ ក្រោមចំណុះអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ត្រូវចូលរួមអនុវត្តផែនការអភិវឌ្ឍន៍នេះតាមតួនាទី និងភារកិច្ចដូចបានកំណត់ក្នុងបទប្បញ្ញត្តិជាធរមានរៀងៗខ្លួន។ ក្នុងនោះផងដែរ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** មានគោលដៅចំនួន ៤ ដែលបានដាក់ចេញទៅ÷

- **គោលដៅទី១.** ការកសាងនិងអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស។
- **គោលដៅទី២.** ការអភិវឌ្ឍចំណេះដឹងពាក់ព័ន្ធនឹងមុខងារសវនកម្ម ព្រមទាំងការពង្រឹងនិងពង្រីកការបញ្ជ្រាបការយល់ដឹង និងផ្សព្វផ្សាយមុខងារសវនកម្មជូនបុគ្គលជាប់ពាក់ព័ន្ធ។
- **គោលដៅទី៣.** ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការតាមដានត្រួតពិនិត្យពិនិត្យអង្គភាពក្រោមឱវាទ **អ.ស.ហ.**។
- **គោលដៅទី៤.** ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

# ② យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ(ត)

**២. ការត្រួតពិនិត្យ និងការវាយតម្លៃ**

ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.** សម្រាប់រយៈពេល១០ ឆ្នាំ (២០២១-២០៣០) ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃ។ ការត្រួតពិនិត្យនឹងវាយតម្លៃត្រូវធ្វើឡើងជាប្រចាំ និងនៅពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ។

ក្រុមការងារត្រួតពិនិត្យនឹងវាយតម្លៃ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុង សម្រាប់ រយៈពេល១០ ឆ្នាំ (២០២១-២០៣០) មានសមាសភាពចូលរួមចាប់ពីថ្នាក់ការិយាល័យដល់ថ្នាក់ដឹកនាំអង្គភាព តាមរយៈសេចក្តីសម្រេចរបស់ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.**។

# ② យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ(ត)

**២. ការត្រួតពិនិត្យ និងការវាយតម្លៃ (ត)**

នៅក្នុងឆ្នាំ២០២៥ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** នឹងធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** សម្រាប់រយៈពេល១០ឆ្នាំ (២០២១-២០៣០) ដើម្បីធ្វើបច្ចុប្បន្នភាពទៅជាផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** សម្រាប់រយៈពេល១០ឆ្នាំ (២០២៦-២០៣៥)។

## ៣ សេចក្តីសន្និដ្ឋាន

អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ដើរតួនាទីយ៉ាងសំខាន់ក្នុងការតាមដានត្រួតពិនិត្យ លើការគ្រប់គ្រងអនុលោមភាព សមិទ្ធកម្ម ហិរញ្ញវត្ថុ ធនធានមនុស្ស ទ្រព្យសកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន របស់អង្គភាពក្រោមឱវាទ **អ.ស.ហ.** ក្នុងគោលបំណងផ្តល់ជាអនុសាសន៍ កែសម្អនូវរាល់ចំណុចខ្វះខាតដោយបង្កើននូវជំនឿទុកចិត្ត ការជឿជាក់ និងការទទួលស្គាល់ពីអង្គភាពក្រោមឱវាទ **អ.ស.ហ.** ។

ជាមួយគ្នានេះ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** នឹងកសាងអភិវឌ្ឍស្ថាប័ននិងធនធានមនុស្ស ព្រមទាំងបង្កើននូវកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសវនកម្មជាតិ និងអន្តរជាតិដើម្បីពង្រឹងនិងពង្រីកតួនាទីរបស់ខ្លួនក្នុងគោលដៅចូលរួមចំណែកជាមួយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធានានូវប្រសិទ្ធិភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព ក្នុងការធានានូវទំនុកចិត្តលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**។

# ៣ សេចក្តីសន្និដ្ឋាន (ត)

ដើម្បីឱ្យការអនុវត្តផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** សម្រាប់រយៈពេល ១០ឆ្នាំ (២០២១-២០៣០) នេះទទួលបានជោគជ័យ ទាមទារឱ្យមានធនធានគ្រប់គ្រាន់ ព្រមទាំងការចូលរួមផ្តល់កិច្ចសហការល្អ បង្កលក្ខណៈងាយស្រួល និងផ្តល់ព័ត៌មាន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់អង្គភាពក្រោមឱវាទ **អ.ស.ហ.** និងភាគីពាក់ព័ន្ធផ្សេងទៀត។

# សូមអរគុណ

# THANKS FOR YOUR ATTENTION

អង្គភាពសវនកម្មផ្ទៃក្នុង

INTERNAL AUDIT UNIT






Facebook

Telegram

www.iauoffsa.gov.kh

អាគារ ១៦៨F ជាន់ទី៩ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ